ឯកសារជំនួយស្មារតី
រួមគិត រួមធ្វើ រួមទទួលខុសត្រូវ
លេខ ០៨
ខែសីហា ឆ្នាំ ២០១៤

# សត្វមនុស្ស និងសត្វតិរច្ឆាន

## សង្គមមច្ឆា

(បទពាក្យ ៧)

- ភ្លឺៗផ្លុងៗក្នុងរាត្រី
  ស្រមោលជួងចន្ទក្នុងគង្គា
  គឺចន្ទបូរមីចាកអព្ភា
  រះរាកំសាន្តឋានមច្ឆា។
- ត្រីឆ្តោធំខ្លួនមួនកម្លាំង
  ឆ្អែតមិនទាន់ស្រេកពោះផងណា
  អាងឫទ្ធិអាងរាំងអាងអាជ្ញា
  ឆ្តោតាំងស្រវាម៉ាបែកពោះ។
- កូនត្រីទក់ផ្ទោងត្រីអណ្តែង
  យ៉ាងណាឲ្យតែខ្លួនអញរស់
  កូនគេកូនឯងណាក៏ចុះ
  ឲ្យតែមានឈ្មោះល្បីថាឆ្តោ។
- ឯត្រីខ្លះទៀតមានជឹងក្រាញ់
  កំពឹសកំពុងរត់ស្លន់ស្លោរ
  ទ្រនេលសុទ្ធខ្លាញ់ប៉ុនខាងករ
  ចង្វាឆោឡោលោតប្រញ៉ឹក។
- ឲ្យតែឃើញត្រីធំទាំងហ្នឹង
  វាជ្រុលពេកព្រះអើយជួយនឹក
  ត្រីតូចៗសឹងរត់ចោលទឹក
  ស៊ីគ្មានយប់ព្រឹកទេព្រះអើយ។
- ត្រីដែលតូចៗដូចអភ័ព្វ
  គេត្របាក់ស៊ីធម្មតាហើយ
  គ្មានអ្វីតតប់នឹងគេឡើយ
  ថ្ងៃណាព្រះអើយស្តាប់ពោះវា។
- នេះឧទាហរណ៍ពីសង្គម
  គ្មានចិត្តចេះគិតដូចមនុស្សម្នា
  មច្ឆាតូចធំគ្មានធម្មា
  ទុក្ខ ឬសុខជាថាមិនបាន។
- សូមមច្ឆានៅតែជាមច្ឆា
  សូមកុំជាសង្គមតិរច្ឆាន
  ឯមនុស្សរាជ៏កល្យាណ
  សូមសត្វលោកបានធម៌សន្តោស។

## មនុស្សស៊ីមនុស្ស

(បទពាក្យ ៨)

- សត្វត្រីស៊ីត្រីជារឿងធម្មតា
  រឿងមនុស្សស៊ីមនុស្សនាពេលឥឡូវ
  ឆ្តោស៊ីចង្វាជារឿងទូទៅ
  ជារឿងត្រឹមត្រូវនៃគតិគេ។
- រឿងខ្លាស៊ីក្តាន់មានពេញព្រឹក្សព្រៃ
  រឿងមនុស្សស៊ីមនុស្សជារឿងខុសគេ
  រឿងភេស៊ីត្រីមានពេញទន្លេ
  មិនធ្លាប់លឺទេអស់ញាតិសន្តាន។
- មនុស្សយើងឥឡូវត្រូវតែប្រយ័ត្ន
  មនុស្សលោកសម្បូរមោហ៍ក្នុងសន្តាន
  ព្រោះហេតុវិបត្តិប្លែកហួសការស្មាន
  ប្រៀបសត្វតិរច្ឆានលែងស្គាល់អ្វីល្អ។

- មនុស្សស៊ីមនុស្សកើតឡើងពេញដី    ច្រើនតែសេដ្ឋីស៊ីជនក្រីក្រ
  ស៊ីមិនអោយស្លាប់ស៊ីបែបដាន់ក    ស៊ីបែបធ្វើល្អស៊ីធម៌សុចរិត។
- ឯងខំត្បិតត្បៀតខំឆ្លៀតសន្សំ    ឯគេបន្លំយកគ្មានអាណិត
  កិបកេងគម្រាមបំភ័យបំភិត    ហើយថែមចំតិតគូទបញ្ឈីផង។
- មនុស្សស៊ីមនុស្សស៊ីខុសតិរច្ឆាន    ស៊ីទាំងខ្លួនប្រាណទាំងភូមិរបង
  នេះមិនគិតស៊ីខ្លះខាំមិនមុតផង    មាសពេជ្រកែវកងវាស៊ីទាំងអស់។
- ពេលនេះពួកដែលត្រូវពួកមនុស្សស៊ី    កើតទុក្ខវក់វីមើលគួរស្រណោះ
  ឱ! ព្រះអើយព្រះ! សូមព្រះមើលចុះ    គ្មារស់ទាំងអស់អង្គរប្រេកផ្ទាំង។

## អ្វីម្យ៉ាងដែលអន់ជាងខ្វាក់ភ្នែក

ស្ត្រីចំណាស់ពិការភ្នែកម្នាក់រស់នៅក្បែរសមុទ្រ មានកូនប្រុសម្នាក់ជាអ្នកមុជទឹករកពេក្យក្នុងបាតសមុទ្រ។ អកុសលថ្ងៃមួយកូននោះក៏មានគ្រោះថ្នាក់ដល់ជីវិត។ ស្ត្រីចំណាស់ក៏យកថង់ពេក្យដែលកូនរកបានទៅលក់។ ឈ្មួញបានពិនិត្យ និងបែងចែកពេក្យតាមទំហំ គុណភាព និងរាប់ប្រាក់ឲ្យគ្រប់ចំនួនតាមតម្លៃទីផ្សារ។ ក្រោយពេលស្ត្រីចំណាស់ចេញផុត ជំនួយការឈ្មួញឆ្ងល់ទ្រាំមិនបានក៏សួរថា៖ **"ហេតុអ្វីលោកទិញវាពេញថ្លៃ ពីស្ត្រីដែលមើលពុំឃើញ?"** **"មកពីយើងពុំបានខ្វាក់ភ្នែក មើលពុំឃើញដូចគាត់"** ឈ្មួញតប។

កម្ររកបានណាស់មនុស្សឥឡូវដែលមានសីលធម៌ចំពោះមនុស្សដូចគ្នា។ ពិភពលោកនេះ បានក្លាយជាពិភពហែកហួរគ្នា ដើម្បីត្រឹមតែដណ្តើមគ្នារស់តែប៉ុណ្ណោះ។ ពេលដែលត្រូវបំពានគ្នា គេផ្តល់លេសថានេះវាជាច្បាប់ធម្មជាតិ គឺគេនឹងទាញយកចម្រៀងប្រជាប្រិយខ្មែរមួយបទមកបាំងមុខនោះគឺ សូរិយាល្ងាចថ្ងៃ ទន្សោងគោព្រៃ រកស៊ីជើងភ្នំ ស៊ីតូចតាមតូច ស៊ីធំតាមធំ រកស៊ីជើងភ្នំ ល្បះព្រិចខ្ទីៗ។ នេះវាជាច្បាប់របស់សត្វ ស៊ីតូចតាមតូចស៊ីធំតាមធំ ស៊ីតាមតែឱកាសដែលអាចស៊ីបាន ហើយពេលខ្លះដែលរកស៊ីតាមធំមិនបាន គឺសត្វធំវាស៊ីសត្វតូចតែម្តង ហើយស៊ីទាំងកូនខ្លួនទៅទៀតសត្វខ្លះ។ តើយើងជាមនុស្សនេះត្រូវចម្លងសភាពរបស់សត្វ ត្រង់ចំណុចនេះមកដាក់ខ្លួនអញ្ចឹងទៅឬ? ឲ្យតែប្រទះអីស៊ីកើតដឹងតែពីត្របាក់ចឹងទៅឬ? លោភលន់ខ្លួនឯង កេងប្រវ័ញ្ចគ្នាខ្លួនឯង ជិះជាន់គ្នាខ្លួនឯង ឈ្នានីសគ្នាទៅវិញទៅមកខ្លួនឯង ចិត្តអាក្រក់ខ្លួនឯង ដណ្តើមរបស់គេខ្លួនឯង រំលោភគេខ្លួនឯង តែបែរជាផ្តល់លេសមកថាមើលសត្វទៅវាស៊ីតូចតាមតូចស៊ីធំតាមធំតែអញ្ចឹង!!! គ្មានវាចានឹងថ្លែងមែនសត្វមនុស្សនេះ!!!

មនុស្សខ្ពើមសត្វខ្លាំងណាស់ ព្រោះគេយល់ថាវាកំរោលគួរឲ្យស្អប់ខ្ពើម ដែលការពិតគឺមនុស្សនេះហើយ ដែលអាក្រក់ក្រៃណាអាក្រក់ខ្លាំងជាងសត្វព្រៃទៅទៀត ពេលណាដែលចិត្តរបស់គេមិនទាន់បានអប់រំ។ សត្វវាធ្វើសកម្មភាពទៅតាមតែសភាវគតិ គឺធ្វើអំពើ ធ្វើសកម្មភាព ទៅតាមតែទម្លាប់របស់ជំនាន់មុន។ បើកើតមកឃើញដូនតាឪពុកម្តាយធ្វើបែបណាក៏ធ្វើតាម។ ដោយសារសត្វវាមិនចេះគិត យើងបន្ទោសវាមិនបានទេថា វាមិនចេះផ្លាស់ប្តូរទៅរកអ្វីដែលកាន់តែប្រសើរជាងមុន។ ប៉ុន្តែមនុស្សស្ថិតក្នុងលក្ខខណ្ឌខុសពីសត្វ គឺមនុស្សមានវិចារណញ្ញាណដែលសត្វមិនមាន មនុស្សចេះគិតហើយមនុស្សមានលទ្ធភាពធ្វើទៅតាមការគិតរបស់ខ្លួន។ ទៅហួសពីលក្ខណៈរបស់សត្វឆ្ងាយយ៉ាងនេះហើយ តែសត្វមនុស្សនេះ ពិតជាមិនមានការខ្មាសអៀន មិនចេះទទួលខុសត្រូវលើទង្វើរបស់ខ្លួនឯងមែន។ ចម្រៀងប្រជាប្រិយនេះ គេច្រៀងរៀបរាប់ ពីធម្មជាតិ ពីព្រៃភ្នំ ពីសកម្មភាពសត្វព្រៃដែលរស់នៅ

តែមនុស្សបែរជាឆ្លៀតទាញចំណុចនេះមកទុកបិតបាំងទង្វើថោកទាបរបស់ខ្លួនកើត។ ឱ! សត្វមនុស្សអើយ អើយសត្វមនុស្ស!

ការឆ្លើយតបនឹងតណ្ហា ការស្រេកឃ្លាន ការស្រលាញ់ ការឈឺចាប់ ការភ័យខ្លាចជាដើម វាបង្កើតជាសភាវគតិនៃការទ្រទ្រង់ជីវិត។ បើត្រឹមតែដើម្បី "ឲ្យតែរស់" ទង្វើរបស់មនុស្សវាមិនខុសអីពីទង្វើរបស់សត្វព្រៃឡើយ។ មនុស្សក៏ជាសត្វមួយប្រភេទដែរ តែជាប្រភេទសត្វដែលមានកម្រិតខ្ពស់ជាងសត្វតិរច្ឆាននានា។ មនុស្សលើសពីសត្វត្រង់មនុស្សមានខួរក្បាល ដែលចេះគិតពិចារណាបែងចែកខុស និងត្រូវមានទស្សនៈ មានរូបារម្មណ៍ ឯបេះដូងមនុស្សមានមនោសញ្ចេតនា ការអាណិតស្រលាញ់ មេត្តា ករុណា ហើយមនុស្សមានឱកាសបណ្តុះបញ្ញា ហើយដោយសារការរីកដុះដាលនៃបញ្ញា ធ្វើឲ្យមនុស្សធ្វើការតបស្នងនឹងសភាវគតិដែលដូចសត្វ កាន់តែតិចទៅៗ ឯគុណធម៌កាន់តែដុះខ្ពស់ទៅៗ ដែលធ្វើឲ្យមនុស្សមានគំលាតពីសត្វឆ្ងាយទៅឆ្ងាយទៅ។

ឱ! លោកមនុស្សអើយ អើយលោកមនុស្ស! យើងបានធ្វើដំណើរមកឆ្ងាយពីសត្វណាស់ទៅហើយ ទាំងផ្នែកកម្រិតបញ្ញា ទាំងផ្នែកមនោសញ្ចេតនា។ កាលពីដំបូងៗមនុស្សមិនទាន់ចេះបង្កើតគ្រួសារនៅឡើយទេ ពេលដែលមនុស្សចាប់ដុះមនោសញ្ចេតនា ចេះចងក្រងគ្រួសារ វាចង្រៃអ្វីហ្ន៎! ទើបគំនិតអាត្មានិយមដែលគិតថា អញ! រៀបចំបង្កើតគ្រួសារអញ! វាកើតមកអោបគ្នាមកដែរ ម្តេចមិនគិតត្រឹមតែរៀបចំបង្កើតគ្រួសារ ដោយមិនបាច់ចាំថាគ្រួសាររបស់អញហ្ន៎? ពេលវេលាកាន់តែទៅមុខយូរទៅៗហើយ អ្វីៗវិវត្តទៅមុខរហូត ឯចិត្តកំណាញ់ ចិត្តអាក្រក់ ចិត្តអាត្មានិយមក៏កាន់តែរីកធំទៅៗដែរ។ តើយើងចេះតែបន្តលោភៈ ទោសៈ និងមោហៈនេះ ឲ្យកាន់តែធំទៅៗដោយមិនគិតរកផ្លូវចាកចេញពីវាឬ?

មានបុគ្គលត្រាស់ដឹងមួយអង្គ ដែលនឿយណាយនឹងជីវិតដែលវាចេះតែត្រាច់ចរឥតគោលដៅ លិចអណ្តែតៗតាមតែកម្លាំងកម្ម ហើយលោកបានប្រើភាពអំណត់ និងការព្យាយាមដ៏ខ្លាំងក្លា ក្នុងការស្វែងរកមាគ៌ារំលត់ទុក្ខនេះ។ ព្រះអង្គ បានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ ហើយព្រះអង្គបានភាគទានដល់មនុស្សលោក នូវមាគ៌ាឈានទៅការរំលត់ទុក្ខ នោះគឺព្រះធម៌។ មកដល់សព្វថ្ងៃនេះ ព្រះធម៌នៅជាធរមាននៅឡើយ។ វាជាភ័ព្វសំណាងពន់ពេកណាស់ដែលពួកយើងមិនត្រឹមតែបានកើតជាមនុស្ស តែបានកើតក្នុងប្រទេសមួយ ដែលព្រះធម៌បានផ្សព្វផ្សាយដល់ មិនត្រឹមតែប៉ុណ្ណោះ ប្រទេសកំណើតមួយនេះ មានពាក់ផ្លាកជាក់ព្យួរក្នុងរដ្ឋធម្មនុញ្ញ ថាជាប្រទេសដែលប្រកាន់ព្រះពុទ្ធសាសនាថែមទៀត។ បើទោះបីជាមនុស្សខ្មែរភាគច្រើនលើសលប់ យល់ខុសថាព្រះធម៌ជាសាសនាក៏ដោយ តែយ៉ាងហោចណាស់ បើយើងចង់ក្រោកចេញពីសាសនានេះ យើងនៅមានជង្ហើមដកដែរ។ ឧបមាថាយើងកើតផ្ងាមកក្នុងប្រទេសដែលកាន់សាសនាម៉ូស្លីម គ្រឹស្ត ឬហិណ្ឌូតើវាលំបាកមហាសែនលានលំបាកប៉ុណ្ណា បើយើងចង់ដើរចេញពីសាសនាកំណើត? ទីមួយ វាតិចណាស់ដែលមនុស្សចេះគិតដើរចេញពីសាសនា ទីពីរចាប់ផ្តើមសិក្សារកហេតុផលពីសាសនាកំណើតថែមទៀត តើត្រូវទទួលការរារាំងខ្លាំងប៉ុណ្ណា? ទីបី គិតឃើញច្បាស់ហើយ គេត្រូវហ៊ានអារកាត់ដើរចេញពីសាសនាកំណើតនោះ! ពិតជារយពាន់សែនលានៗឧបសគ្គមែន។ ប៉ុណ្ណេះវាល្មមគ្រប់គ្រាន់ហើយ ឲ្យពួកយើងអរគុណហើយអរគុណទៀតដល់សត្វណានោះ ដែលផ្សំផ្គុំឧបនិស្ស័យឲ្យបានជាយើង មកកើតនៅលើទឹកដីមួយនេះ លើទឹកដីដែលមានការផ្សព្វផ្សាយ និងបង្រៀនព្រះធម៌ដល់ និងមានជាប់គ្រាប់ពូជព្រះធម៌បន្តិចបន្តួចមកជាប់ក្នុងកំណើតនេះ។

យើងអាចសរុបព្រះធម៌មកត្រឹមបីចំណុចធំៗគឺ សព្វបាបស្សអករណំ (ការមិនធ្វើអំពើអាក្រក់) កុសលស្សូបសម្បទា (ការធ្វើតែអំពើជាកុសល) និងសចិត្តបរិយោទបនំ (ការសំអាតចិត្ត)។ តើដូចម្តេចទៅហៅថា ការមិនធ្វើអំពើអាក្រក់? តើដូចម្តេចទៅហៅថា ការធ្វើតែអំពើជា

កុសល? ដើម្បីមិនធ្វើអំពើអាក្រក់ ធ្វើតែអំពើជាកុសលទៅបាន គឺត្រូវស្គាល់ថាអ្វីទៅជា អំពើអាក្រក់? អ្វីទៅជាអំពើកុសល? មិនត្រឹមតែទង្វើតាមកាយ និងវាចាប៉ុណ្ណោះទេ ដែលរាប់ថាជាទង្វើ តែទង្វើតាមផ្លូវចិត្ត តាមផ្លូវមនោក៏ត្រូវរាប់ថាជាទង្វើផងដែរ ហើយទង្វើតាមផ្លូវចិត្តត្រូវបានរាប់ថាជាប្រធាន ជាដើមចមនៃទង្វើតាមផ្លូវកាយ និងវាចាទៅទៀត។ បើចិត្តយើងពោរពេញដោយកំហឹង កំហឹងនោះវានឹងមិនដេកសំងំតែក្នុងខ្លួនយើងម្នាក់ឯងឡើយ មិនថាយើងពូកែសម្ដែងល្ខោនថាមិនមានកំហឹង រហូតជាប់ពានរង្វាន់អូស្ការកម្រិតពិភពលោក ថាចេះសម្ដែងជាតួមិនចេះខឹងយ៉ាងណាក៏ដោយ ក៏កំហឹងនោះវានឹងរកផ្លូវស្វែងចេញមកខាងក្រៅទាល់តែឃើញ។ តើអ្នកដឹងទេថាពេលយើងខឹងក្រោធនរណាម្នាក់ មិនមែនថាម្នាក់នោះគេគួរអោយខឹងក្រោធ និងស្អប់ខ្ពើមឡើយ តែវាមកពីមានភ្នំភ្លើងខឹងក្រោធនិងស្អប់ខ្ពើមដ៏ធំមហិមា កប់នៅក្នុងចិត្តរបស់យើងជាយូរមកហើយនោះ ហើយវាតែងស្វែងរកមុខផ្ទុះចេញមកក្រៅជារឿយៗ។ ឯមនុស្សអភ័ព្វម្នាក់នោះ គេមកបង្ហាញខ្លួនចំពោះមុខយើងចំវេលាដែលភ្នំភ្លើងខឹងក្រោធ និងស្អប់ខ្ពើមនោះវាកក្រើកតែប៉ុណ្ណោះ គេគ្រាន់តែជា "រន្ធបង្ហុយ" ពីភ្នំភ្លើងខឹងក្រោធ និងស្អប់ខ្ពើមដ៏ធំមហិមាកប់នៅក្នុងចិត្តរបស់យើង គឺគ្រាន់តែឃើញមុខ ឬឮសម្លេងម្នាក់នោះភ្លាមយើងក៏ក្ដៅក្រហាយក្នុងចិត្ត ទប់មិនបានវាហៀរចេញមកជាវាចាទ្រគោះបោះបោកគំរោះគំរើយ ឬរហូតដល់ដេរប្រទេចផ្ដាសារ ហើយបើភាគីម្ខាងទៀតនោះ បើកគ្រប់គម្របភ្នំភ្លើងគេដែរ ទង្វើអកុសលតាមផ្លូវកាយរបស់ពួកយើង ក៏ចាប់ផ្ដើមឡើងមិនខាន។ ផ្ទុយទៅវិញ បើចិត្តយើងពោរពេញដោយមេត្តា ករុណា ការអាណិត ការស្រលាញ់ ការចែករំលែកវិញ ពេលដែលយើងឃើញមនុស្សជុំវិញគេជួបការលំបាក ចិត្តយើងក៏គិតព្រួច ថាចង់ជួយគេបែបនេះ ចង់ជួយគេបែបនោះ ពេលនោះយើងនឹងស្វែងវាចេញតាមផ្លូវវាចា ជាពាក្យលើកទឹកចិត្ត លួងលោមពាក្យពីរោះក្នុងន័យចង់ជួយបុគ្គលដែលគួរឲ្យអាណិត គួរឲ្យជួយនោះ ហើយសកម្មភាពតាមកាយ ជាសកម្មភាពជួយក៏កើតឡើង។ អ្វីៗកើតពីទង្វើតាមផ្លូវចិត្តទាំងអស់។

បើស្អប់អំពើអាក្រក់ ដោយនិយាយថាស្អប់តែម្យ៉ាងមិនទាន់គ្រប់គ្រាន់ទេ។ ស្អប់អំពើអាក្រក់ គឺមិនធ្វើអំពើនោះខ្លួនឯងផង មិនអនុញ្ញាតឲ្យគេធ្វើអំពើនោះផង។ ការមិនធ្វើអំពើអាក្រក់មិនមែន មិនធ្វើដោយហេតុថា បើធ្វើទៅសាសនាគេថាទៅចុះនរកឡើយ តែគឺមិនធ្វើព្រោះតែអំពើនោះ វានឹងនាំទុក្ខទោសដល់ខ្លួនអ្នកប្រព្រឹត្តផង នាំទុក្ខដល់មនុស្សជុំវិញផង។ ការនាំទុក្ខទោសដល់ខ្លួនអ្នកប្រព្រឹត្តនោះគឺនាំឲ្យបង្កើតគំនរទោសៈ និងលោភៈបន្ថែមទៅក្នុងចិត្ត។

ចុះសកម្មភាព "ធ្វើជាជួយ" វិញវាចេញមកបែបណាដែរ? ដំបូងអ្នកដែលមានគំនិតបែបនេះ ច្បាស់ជាគិតទៅដល់លទ្ធផល ថាបើធ្វើជាជួយគេបែបនេះៗ នោះគេនឹងបានទទួលបែបនោះៗត្រលប់មកវិញ។ គិតបែបនេះហើយទើបគេចាប់រៀបឧបាយឲ្យដូចគេជួយមែនៗ។ អាស្រ័យហេតុនេះហើយ ទើបយើងត្រូវសម្លឹងទៅកមនោរបស់មនុស្ស កុំយកត្រឹមភ្នែកទៅមើល បើយកតែភ្នែកទៅមើល វាច្បាស់ជាឃើញត្រឹមតែសកម្មភាពដោយកាយតែប៉ុណ្ណោះ ឯការប្រើបេះដូងមើល ទើបអាចមើលបេះដូងមួយទៀតឃើញ។ ការធ្វើតែអំពើកុសល អំពើល្អ គឺធ្វើតែអំពើណាដែលមិនត្រឹមតែមិននាំទុក្ខទោសដល់ ខ្លួនអ្នកប្រព្រឹត្តផង មិននាំទុក្ខដល់មនុស្សជុំវិញផង ថែមទាំងជាអំពើណាដែលអាចទៅជួយមនុស្សជុំវិញបានផង។ ធ្វើទង្វើល្អ មិនមែនព្រោះតែធ្វើទង្វើនោះទៅ សាសនាគេថានឹងបានទៅឋានសួគ៌ឡើយ តែធ្វើព្រោះស្រលាញ់អំពើល្អនោះ គឺទង្វើនោះវាបានដុះជាប់កប់ក្នុងសណ្ដានចិត្ត ក្លាយជាប្រក្រតីនៃចិត្តរបស់យើងទៅហើយ។

ការស្រលាញ់អំពើល្អ វាស្ដែងចេញមកជាធាតុ ៥ យ៉ាង គឺស្គាល់ថាអំពើបែបណាជាអំពើល្អ ដាំបណ្ដុះអំពើល្អដែលមិនទាន់មានឲ្យដុះ កុំឲ្យវានៅត្រឹមធ្វើព្រោះសុជីវធម៌ ប្រព្រឹត្តតែអំពើល្អ ជួយខ្នះខ្នែងក្នុងការពង្រីកអំពើល្អនោះ និងធាតុចុងក្រោយ គឺការពារអំពើល្អនោះ មិនឲ្យមនុស្សទុច្ចរិតមកបំពារបំពាន និងបំបាត់ទៅវិញ។ មិនធ្វើអំពើ

អាក្រក់ហើយ ធ្វើតែអំពើល្អមិនទាន់រួចខ្លួនទេ ដំណាក់កាលបន្ទាប់គឺការសំអាតចិត្ត។ តើសំអាតចិត្តដូចម្តេច? ចិត្តនេះវាប្រលាក់ដោយអ្វី? ហេតុអ្វីទើបត្រូវសំអាតចិត្ត? បើមិនសំអាតតើយ៉ាងមេច? យើងរស់នៅសព្វថ្ងៃ យើងដឹងត្រឹមតែចិត្តផ្នែកសើលើតែប៉ុណ្ណោះ យើងមិនដឹងទេថានៅទីជម្រៅចិត្តរបស់យើងធ្វើការគ្រប់ពេល វាប្រតិកម្មគ្រប់ខណៈ ហើយប្រតិកម្មនោះហើយដែលបង្កើតនូវសង្ខារជាសង្ខារលោភៈ និងសង្ខារទោសៈគ្រប់ពេល។

ព្រះសម្មាសម្ពុទ្ធព្រះបរមគ្រូនៃយើង បានបង្ហាញមាគ៌ារំលត់ទុក្ខ ដោយចូលទៅគាស់រំលើង ដល់ឫសគល់នៃទុក្ខតែម្តង គឺគាស់អស់ឫសគល់នៃលោភៈ ទោសៈ និងមោហៈ។ មាគ៌ាតែមួយគត់ទៅរំលត់ទុក្ខ គឺការទៅបដិបត្តិវិបស្សនា។ នេះទើបជាការបដិបត្តិធម៌ពិតប្រាកដត្រឹមត្រូវ ឯការបន់ស្រន់បួងសួង រៀបរោងធ្វើពិធី សូត្រមន្តស្រូស្រៗនាំគ្នាយកមាសទៅបញ្ចុះនៅគល់ពោធិនៅប្រទេសឥណ្ឌា នោះមិនមែនជាការបដិបត្តិធម៌ឡើយ។ សព្វថ្ងៃនេះ ការបង្រៀនពីបច្ចេកទេសវិបស្សនា តាមទម្រង់ដើមនៃព្រះសម្មាសម្ពុទ្ធព្រះបរមគ្រូនៃយើងនៅមាននៅឡើយ។ មជ្ឈមណ្ឌលវិបស្សនានៅប្រទេសកម្ពុជាយើងក៏មានដែរសព្វថ្ងៃ។ ព្រះធម៌មានលក្ខណៈជាអកាលិកោ គឺព្រះធម៌អោយផលដោយមិនរង់ចាំកាលឡើយ។ វេលានេះគឺជាង ២៥០០ ឆ្នាំមកហើយ ដែលព្រះសម្មាសម្ពុទ្ធបានបរិនិព្វាន តែព្រះធម៌នៅតែផ្តល់ផលដល់អ្នកដែលបដិបត្តិដោយត្រឹមត្រូវ និងដោយអំណត់ដដែល។ មិនថាអ្នកជាបណ្ឌិត ឬជាមនុស្សសាមញ្ញ ត្រឹមតែអ្នករៀបចំខ្លួនដើរលើមាគ៌ា នោះនឹងទទួលបានផលដោយមិនរើសមុខ នេះគឺវិញ្ញូហិ ដែលជាគុណសម្បត្តិមួយរបស់ព្រះធម៌។

សូមអោយគ្រាប់ពូជព្រះធម៌របស់ពួកយើង ចេះតែចម្រើនឡើងៗ ដើម្បីបានជាប្រយោជន៍ដល់សព្វសត្វ!

## គតិផ្សេងៗ

ក្នុងជីវិតមនុស្សត្រូវរស់ នៅក្នុងភាពតឹងតែងពីរយ៉ាង និងក្នុងភាពអធ្យាស្រ័យមួយៈ តឹងតែងចំពោះខ្លួនឯង និងតឹងតែងចំពោះសភាវៈអាក្រក់ទាំងឡាយ ហើយអធ្យាស្រ័យចំពោះកំហុសរបស់មនុស្សល្អ ឬមនុស្សដែលគួរបានទទួលនូវធម៌អភ័យ។

In the course of our life, we need to be serious with two types of attitudes and one type of forgiveness. While we are serious with ourselves, and crooked acts, we forgive the mistakes of good people or those who deserve our forgiveness.

ពិភពលោកមានអ្វីៗគ្រប់គ្រាន់សម្រាប់តម្រូវការរបស់មនុស្សគ្រប់គ្នា ប៉ុន្តែមិនគ្រប់គ្រាន់សម្រាប់ការលោភលន់របស់មនុស្សសូម្បីតែម្នាក់សោះឡើយ។

The Earth provides enough to satisfy all human's need, but not enough for a man's greed.

ពិភពលោកនេះនឹងមិនត្រូវបានបំផ្លាញដោយមនុស្សអាក្រក់ប៉ុណ្ណោះឡើយ ប៉ុន្តែវាត្រូវបានបំផ្លាញដោយអ្នកដែលតាំងខ្លួនជាមនុស្សល្អ ឈរមើលមនុស្សអាក្រក់ទាំងនោះបំផ្លាញដោយមិនធ្វើអ្វីសោះ។

The world will not be destroyed by those who do evil, but by those who watch them without doing anything.

ជំងឺគិតតែប្រយោជន៍ផ្ទាល់ខ្លួនតែម្យ៉ាង គឺគ្រប់គ្រាន់សម្រាប់ឲ្យជាតិមួយស្លាប់បានហើយ។

Selfishness alone is sufficient to bring apocalypse upon a nation.

## ស្វែងយល់បន្ថែម

(១). វិទ្យុសំបុកឃ្មុំ FM105 MHz ភ្នំពេញ: ម៉ោង ២ ដល់ម៉ោង ៣ រសៀល
(២). គេហទំព័រ: www.camldp.org
(៣). YouTube: ខឹម វាសនា ឬ Khem Veasna
(៤). Paltalk: Room Koun Khmer និង/ឬ
(៥). សារអេឡិចត្រូនិក: camldp3@gmail.com

# សំណើចចំអករបស់សត្វ
(បទកាកគតិ)

- ស្រុកមនុស្សទេតើ! ស្មានថាគ្រាន់បើ មានទៅប៉ុន្មាន!
ដណ្តើមគ្នារស់ ដូចតែតិរច្ឆាន ម្តេចលោករាប់អាន
ថាមនុស្សប្រសើរ?
- ឱ! ស្រុកមនុស្សសោះ ស៊ីគ្នាស្រស់ៗ ដូចសត្វដែរតើ
ថាសត្វទៅចុះ រស់ឥតប្រសើរ តូចធំឥតស្មើ
តាមតែកម្លាំង។
- ធំអាងអំណាច តូចអាងខ្លបខ្លាច ឥតអាចប្រឆាំង
ធំស៊ីតាមធំ តូចកុំតតាំង តូចគ្មានកម្លាំង
តូចស៊ីតាមតូច។
- ឯស្រុកមនុស្ស ស៊ីឃ្លានតាមផុះ រស់ឆាតែខូច
រស់ដូចតែគ្នា តែវាមិនដូច នឹងសត្វត្រង់ខូច
ខូចរឿងមនុស្សធី។
- មនុស្សស៊ីទាំងអស់ ស៊ីកេរស៊ីកោះ ស៊ីឥតសល់អ្វី
ស៊ីឆ្អែតស៊ីធ្នា ស៊ីជាតិទឹកដី ស៊ីព្រឹក្សស៊ីព្រៃ
ស៊ីព្រោះពោះឃ្លាន៕

## គតិផ្សេងៗ

ការផ្តល់ទិន្នន័យខុសៗទៅឲ្យប្រជាពលរដ្ឋជាប្រចាំ គឺជាការបំផ្លាញជាតិដល់ឫសគល់។
Closing the minds of people and providing them with false informations will ensure destruction to the very core of a country.

ផលប្រយោជន៍ផ្ទាល់ខ្លួនរបស់យើងម្នាក់ៗ អាចមិនមែនជាផលប្រយោជន៍ជាតិ ប៉ុន្តែផលប្រយោជន៍ជាតិច្បាស់ណាស់ ជាផលប្រយោជន៍របស់យើងគ្រប់គ្នា។
Our personal interests may not be the national interest; nevertheless the national interest is clearly for everyone's benefit.

មនុស្សទាំងឡាយតែងតែការពារទង្វើរបស់គេ តែការបែងចែកថាវាសមហេតុផល រឺអត់ ជាតួនាទីរបស់អ្នក។
Everyone will justify their acts—but whether or not they are justifitable is your risk.

អ្នកនៅស្ងៀមមិនចូលរួមកសាងសង្គមឲ្យមានការរីកចម្រើន មានន័យថាអ្នកបានចូលរួមបំផ្លាញសង្គមអ្នកហើយ។
It is known that you ruin your nation if you fail to take part in building it.